# ព្រះមហាវិរិយបណ្ឌិតោប៉ាងខាត់
## (១៩១០-១៩៧៥)

ដោយ

បណ្ឌិត**ឃើងហុកឌី**

«អ្នកប្រាជ្ញ កាលបើស្វែងរក វិជ្ជានិងទ្រព្យ គប្បីគិតថា ដូចជាខ្លួនមិនចាស់មិនស្លាប់, កាលបើស្វែងរកធម៌ គប្បីគិតថា ខ្លួនត្រូវមច្ចុចាប់ក្របួចសក់បោកសម្លាប់ឥឡូវនេះហើយ។»[1]
*ស្រីហិតោបទេស*

## ជីវប្រវត្តិសង្ខេប

កុមារខាត់កើតរវាងឆ្នាំ១៩១០នៅភូមិភ្នំដិល,ស្រុកបាធាយក្នុងខែត្រកំពង់ចាម។បិតានាមប៉ាងនិងមាតានាមអុង។ដល់ធំដឹងក្តីហើយកុមារនេះបានបួសរៀនក្នុងសំណាក់ពុទ្ធសាសនាហើយបានប្រឡងជាប់ចូលរៀននៅសាលាបាលី ជាន់ខ្ពស់ទៀតព្រះភិក្ខុប៉ាងខាត់បានប្រឡងជាប់ចូលរៀនជាសាស្ត្រាចារ្យភាសាបារាំងដោយបានពិន្ទុល្អប្រសើរទៀតផងដូចមានសេចក្តីបញ្ជាក់ក្នុងអត្ថបទលោកចុះផ្សាយក្នុងទស្សនាវដ្តីពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ«មិត្តសាលាបាលី»[2] ឆ្នាំទី២,លេខ១,ខែមករា,១៩៥១,ទំព័រ២៦ថា«កាលខ្ញុំ ប្រឡងចូលរៀនសាលាបាលីជាន់ខ្ពស់ហើយ ខ្ញុំត្រូវ

---

[1] ភិក្ខុប៉ាងខាត់,*ស្រីហិតោបទេស*,ភាគ១,បណ្ណាគារគីមគី,១៩៥២,ទំព័រ១១។

[2] *មិត្តសាលាបាលី*ជា ទស្សនាវដ្តីពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរដែលមានលោកឈឹមក្រសេមជាបណ្ណាធិការ,សំណាក់ការនៅលេខ៣៩៣វិថីឧញ៉ាពេជ្រ,ភ្នំពេញ។ ទស្សនាវដ្តីអនុមាសនេះបានបង្កើតដំបូងនៅឆ្នាំ១៩៥០ដោយមានសមាជិកសកម្មដូចជាលោកប៉ាយប៉ុក,លោកកែនេត្រ,លោករឹមគិន,ភិក្ខុប៉ាងខាត់ជាដើម។ដំឡៃជាវប្រចាំឆ្នាំ១០០រៀល។

ប្រឡងចូលរៀនភាសាបារាំងផ្នែកខាងធ្វើគ្រូទៀតកាលនោះខ្ញុំមានសំណាងបានពិន្ទុប្រសើរជាងគេ»[3]។ ពេលដែលភិក្ខុ ប៉ាំងខាត់ សិក្សាក្នុងក្រុងភ្នំពេញលោកសំណាក់នៅវត្តឧណ្ណាលោមក្នុងកុដិព្រះពោធិវ័ង្សហ្វូតតាត ហើយលោកជាសិស្សគណ ព្រះពោធិវ័ង្ស។

បន្ទាប់ពីបានសិក្សាចប់នៅសាលាបាលីជាន់ខ្ពស់,ភិក្ខុប៉ាំងខាត់បានធ្វើជាសាស្ត្រាចារ្យភាសាបាលីជាដំបូងនៅវត្តប្រាង្គក្នុងស្រុកឧដុង្គ[4]។

ភិក្ខុប៉ាំងខាត់ជាព្រះសង្ឃគម្រូខ្មែរមួយអង្គនិងជាសាស្ត្រាចារ្យដ៏ឆ្នើមប្រកបដោយវិជ្ជាខ្ពង់ខ្ពស់ទូលំទូលាយទាំងខាងផ្លូវលោកទាំងខាងផ្លូវធម៌ដោយព្រះអង្គចេះភាសាអង់គ្លេស,ភាសាបារាំង,បាលី,សំស្ក្រឹត,សៀម,ខ្មែរបុរាណ។ល។

## តួនាទីក្នុងឧត្តមសិក្សានិងក្នុងការស្រាវជ្រាវ

### ក្នុងឧត្តមសិក្សា

ភិក្ខុប៉ាំងខាត់ធ្វើជាសាស្ត្រាចារ្យភាសាសំស្ក្រឹតនិងភាសាបាលីនៅសាកលវិទ្យាល័យព្រះសីហនុរាជភ្នំពេញ។

---

[3]ភិក្ខុប៉ាំងខាត់,«គួរកសាងអនុស្សាវរីយ៍ព្រះមហាវិមលធម្មថោងឬទេ ?», *មិត្តសាលាបាលី*, ឆ្នាំទី២,លេខ១,ខែមករា,១៩៥១,ទំព័រ២៦។

[4] យោងតាមសំដីលោកមហាឡាយគ្រី(កើតនៅឆ្នាំ១៩២៩គឺក្នុងឆ្នាំមមែ)ជាសិស្សលោកតាប៉ាំងខាត់ចាស់។ លោកមហាឡាយគ្រីកាលនៅបួសរៀនសំណាក់នៅកុដិលេខ៩ដែលជាកុដិ លោកតាប៉ាំងខាត់។ពេលដែល លោកតាប៉ាំងខាត់ធ្វើដំណើរសិក្សានៅឥណ្ឌានាឆ្នាំ១៩៦៣ភិក្ខុឡាយគ្រីបានយកសៀវភៅ*ជីវិតម៉ែ*របស់លោកតាប៉ាំងខាត់ទៅបោះពុម្ពផ្សាយឡើងវិញ។ក្រោយមកនៅ«សម័យសាធារណរដ្ឋខ្មែរ» មហាឡាយគ្រីបានទៅបំពេញការសិក្សានៅ ឥណ្ឌារហូតដល់បានសញ្ញាប័ត្រថ្នាក់បណ្ឌិតហើយបានទៅនៅសហរដ្ឋអាមេរិក។លោកបានចាកសិក្ខាបទមកជាគ្រហស្ថហើយមានគ្រួសារបានបុត្រី៣នាក់។

ទន្ទឹម នឹង ភារកិច្ច នៅ សាកលវិទ្យាល័យ ព្រះសីហនុរាជ ភិក្ខុប៉ាងខាត់បានមកបង្រៀន«ការសិក្សាអក្សរថ្មនិងខ្មែរបុរាណ»ហើយនិង«ប្រវត្តិសាសនាឥណ្ឌា,ខ្មែរ»នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។[5]

ភិក្ខុប៉ាងខាត់បានបង្រៀនភាសាបាលីជាច្រើនឆ្នាំនៅសាលាបាលីជាន់ខ្ពស់នៅភ្នំពេញដែលមានព្រះពោធិវ័ង្សហួតតាតជាចាងហ្វាងសាលាបាលីជាន់ខ្ពស់និងជាអធិបតីក្រុមជំនុំព្រះត្រៃបិដកគឺជាអតីតគ្រូអាចារ្យលោក។បន្ទាប់មកលោកបានបង្រៀនភាសាសំស្ក្រឹតនៅសាកលវិទ្យាល័យព្រះសីហនុរាជ ក្រុង ភ្នំពេញ រហូតដល់ឆ្នាំ១៩៧៥ (សូមអានបញ្ជីស្នាដៃលោក)។

ភិក្ខុប៉ាងខាត់បាន បង្រៀននៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រភ្នំពេញរហូតដល់ឆ្នាំ១៩៧៥នូវមុខវិជ្ជា២គឺមានបង្រៀនពី៖

១)អក្សរថ្មនិងភាសាខ្មែរបុរាណ,ខ្មែរកណ្តាលសម្រាប់និស្សិតរៀនយកសញ្ញាប័ត្រសិក្សាជាន់ខ្ពស់ផ្នែកវេយ្យករណ៍និងនិរុទ្ធិវិទ្យា។

២)ប្រវត្តិសាស្ត្រសាសនាឥណ្ឌាខ្មែរ សម្រាប់និស្សិតរៀនយកសញ្ញាប័ត្រសិក្សាជាន់ខ្ពស់ផ្នែកវប្បធម៌អរិយធម៌ខ្មែរ។

នេះជាកម្មវិធីដែលភិក្ខុ ប៉ាងខាត់ បាន បង្រៀនដល់និស្សិតរៀនយកសញ្ញាប័ត្រសិក្សាជាន់ខ្ពស់ផ្នែកវេយ្យាករណ៍និងនិរុត្តិវិទ្យាគឺមាន៖

ក)ពាក្យសំស្ក្រឹតក្នុងអត្ថបទ«ទសជាតក»,

ខ)ពាក្យបាលី ក្នុងអត្ថបទ«ទសជាតក»,

គ)ខ្មែរបុរាណគឺសិក្សាតាំងអំពីឯកសារជាភាសាខ្មែរបុរាណនិងការវិវត្តន៍នៃភាសានេះតាំងពីសតវត្សរ៍ទី៧ដល់សតវត្សទី១៨-១៩៖

១)មុនសម័យអង្គរគឺមានសិលាចារឹកទាំងឡាយក្នុងកំឡុងសតវត្សរ៍ទី៧/ទី៨ដូចជា

សិលាចារឹកនៅអង្គរបុរីខាងដើមសតវត្សរ៍ទី៧គ.ស. ៦១១។

---

[5] សូមអាន*កំរងពត៌មាននៃមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រភ្នំពេញ* ឆ្នាំសិក្សា១៩៧០-១៩៧១, ទំព័រ៣៧-៣៨និងទំព័រ៤៣-៤៥។

សិលាចារឹករជ្ជកាលព្រះភវវរ្មនទី២គ.ស. ៦៣៨។

សិលាចារឹកប្រាសាទប្រាំល្វែង,ថាប់ម៉ូយ,វាលភក់កូសាំងស៊ីនក្នុងកំឡុងសតវត្សរ៍ទី៧/ទី៨។

សិលាចារឹកព្រៃមៀនស្រុកទ្រាំង,កំពតសតវត្សរ៍ទី ៨ គ.ស.៧២៦។

២)សម័យអង្គរមានសិលាចារឹកទាំងឡាយក្នុងសតវត្សទី៩ដល់១៥គឺមាន

អត្ថបទសិលាចារឹកជាភាសាខ្មែរបុរាណសម័យអង្គរក្នុងរជ្ជកាលផ្សេងៗ និងចលនាអក្សរសិល្ប៍ក្នុងសម័យអង្គរជាពិសេសរឿងរាមកេរ្តិ៍និងរឿងមហាភារតយុទ្ធជាដើម។

៣)ក្រោយសម័យអង្គរគឺមាន

អត្ថបទសិលាចារឹកខ្មែរក្រោយសម័យអង្គរដែលបានបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យហៅថាសិលាចារឹកនគរវត្តក្នុងអំឡុងសតវត្សរ៍ទី១៦ដល់ទី១៨។

ចលនាអក្សរសិល្ប៍ផ្សេងៗក្នុងកំឡុងសតវត្សរ៍ទី១៨-១៩។

៤)អំពីទម្រង់និងអក្ខរាវិរុទ្ធនៃភាសាខ្មែរខ្លះអំពីបុរាណកាលមកដល់បច្ចុប្បន្ន។

នេះជាកម្មវិធីដែលភិក្ខុ ប៉ាងខាត់ បាន បង្រៀនដល់និស្សិតរៀនយកសញ្ញាប័ត្រសិក្សាជាន់ខ្ពស់ផ្នែកវប្បធម៌អរិយធម៌ខ្មែរ គឺមាន៖

១)ព្រហ្មញ្ញនិយមគឺមានអរិយធម៌វេទ,មានសាសនាវេទ,អទិទេពវេទ,ពិធីវេទ។ល។

២)ហិណ្ឌូនិយមគឺមានព្រហ្ម,ឥស្វរ(សិវ)និងវិស្ណុ។

៣)ពុទ្ធនិយមគឺមាន

ពុទ្ធសាសនាមហាយាននិងថេរវាទ។ល។[6]

---

[6] សូមអាន *កំរងពត៌មាននៃមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រភ្នំពេញ* ឆ្នាំសិក្សា១៩៧០-១៩៧១, ទំព័រ៣៧-៣៨និងទំព័រ៤៣-៤៥។

### ក្នុងការស្រាវជ្រាវ

ភិក្ខុប៉ាងខាត់ជាអ្នកស្រាវជ្រាវ ដ៏ល្បីល្បាញក្នុងសំណាក់ អ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ។ សាលាបារាំងចុងបូព៌ាប្រទេសបានតែងតាំងលោកជាសមាជិកឆ្លើយឆ្លង (membre correspondant de l´Ecole Française d´Extrême Orient) នៅឆ្នាំ១៩៤៨,១៩៥១និងឆ្នាំ១៩៥៤[7]។

ភិក្ខុប៉ាងខាត់ជាអ្នកប្រាជ្ញជាតិម្នាក់ដែលយើងមិនអាចបំភ្លេចបាន។ លោកបានបន្សល់ទុកស្នាដៃដ៏ច្រើនសម្រាប់ខ្មែរយើងជំនាន់ក្រោយដូចមានបញ្ជីអត្ថបទនានាភ្ជាប់នៅខាងក្រោមនេះស្រាប់។ លោកបានបង្ហាត់បង្រៀនព្រះសង្ឃនិងនិស្សិតនៅសាកលវិទ្យាល័យព្រះសីហនុរាជនិងសាកលវិទ្យាល័យភូមិន្ទជាច្រើនជំនាន់ហើយសិស្សនិងនិស្សិតចាស់របស់លោកក្រោយមកក្លាយខ្លួនជាគ្រូ,ជាសាស្ត្រាចារ្យនិងជាអ្នកស្រាវជ្រាវផ្នែកភាសា,អក្សរសាស្ត្រ,វប្បធម៌អរិយធម៌ខ្មែរជាដើមបានបន្តស្នាដៃលោកតទៅទៀត។ដោយហេតុនេះហើយបានជាមានសិស្សចាស់ខ្លះនៅក្នុងស្រុក,ខ្លះទៀតនៅក្រៅស្រុក(អ៊ឺរ៉ុប,អូស្ត្រាលី,អាមេរិក,អាស៊ី)បានប្រមូលគ្នាចងក្រងសៀវភៅមួយជាស្នាដៃរួមដើម្បីជាគារវកិច្ចដ៏សំខាន់ឧទ្ទិសដល់គុណគ្រូដែលមានឧបការគុណឥតគណនាដល់យើងខ្ញុំ ។

បងប្អូនអ្នកសិក្សាព្រមទាំងប្រជារាស្ត្រនានានៅនឹកឃើញដល់ស្នាដៃលោកដែលទុកជាកេរ្តិ៍ច្រើនជាពិសេសគឺសៀវភៅ*ស្រីហិតោបទេស*៤ភាគ[8]និង *ប្រវត្តិពុទ្ធសាសនានៅកម្ពុជា*[9](ជាភាសាខ្មែរនិងជាភាសាបារាំង)។

---

[7] Il était membre correspondant de l’Ecole Française d’Extrême-Orient en 1948, 1951, 1954 (cf. *Chercheurs d’Asie*, Paris, Publ. EFEO, 2002, p.307)

[8] *ស្រីហិតោបទេស*, ភ្នំពេញ, គីមគី, ៤ភាគ,១៩៥២-១៩៦១,កថាមុខសរសេរចប់នៅវត្តឧណ្ណាលោមថ្ងៃពុធ៦រោចខែភទ្របទឆ្នាំឆ្លូវឯកស័កពស២៤៥២ត្រូវនឹងថ្ងៃទី២៧ខែកញ្ញាគស១៩៤៩។បោះពុម្ពឡើងវិញនៅ ពុទ្ធសាសនបណ្ឌិត្យ១៩៩៩។សៀវភៅទាំង៤ភាគនេះលោកបាន«បកប្រែពីច្បាប់ភាសាសំស្រ្កឹត**នារាយណៈបណ្ឌិត** ដែលលោកកាសីណាថបាណ្ឌុរង្គបរ័ពបោះពុម្ពលើកទី១០នៅបុំបៃគស១៩២១»ហើយលោកបានផ្ទៀងផ្ទាត់ជាមួយនឹងច្បាប់បកប្រែជាភាសាសៀមរបស់បណ្ឌិតសៀមនាម**នាគប្រទីប**។

តួនាទីក្នុងពុទ្ធសាសនានិងក្នុងនយោបាយ

ក្នុង ពុទ្ធសាសនា

ភិក្ខុប៉ាំងខាត់ឥតមានងារក្នុងរាជាគណៈសង្ឃទេព្រោះលោកមិនមែនជាសង្ឃដែលស្វះស្វែងបុណ្យសក្តិយសសោះឡើយ។ក្នុងសំណេរលោកចារលើនាមលោកថា«ភិក្ខុ»ឬឆាយានាមលោក«វីរិបណ្ឌិតោ»ដែលព្រះសង្ឃទាំងអស់មួយអង្គៗមានឆាយានាមផ្ទាល់មួយប្រចាំជីវិតជាសង្ឃ។

ភិក្ខុប៉ាំងខាត់បានសរសេរអត្ថបទជាច្រើនពន្យល់ពុទ្ធមាមកជនថា«ព្រះពុទ្ធសាសនា»គឺជាវិទ្យាសាស្រ្តនិងបង្ហាញពីតម្លៃសាកលជាឬសគល់ពិតនៃព្រះពុទ្ធសាសនា។តាមសំដីលោកថ្លែងក្នុងមេរៀនស្តីពី«ព្រះពុទ្ធសាសនា»ជាកំណាព្យពាក្យ៩ថា៖

«មានអ្វីលើឈ្មោះ
ហៅហើយពីរោះ
ដូចផ្កាកុលាប
ទោះនឹងហៅអ្វី
កុលាបពីសី
ក្រអូបដដែល»។

ដោយជាអ្នកស្រាវជ្រាវខ្មាតអន្តរជាតិប្រកបវិជ្ជានិងវិធីសាស្រ្តបែបវិទ្យាសាស្រ្តខ្ពង់ខ្ពស់ លោកយកការបកប្រែ *ស្រីហិតោបទេស* របស់លោកទៅ ផ្ទៀងផ្ទាត់នឹងការបកប្រែជាភាសាបារាំងរបស់លោកឡង់សឺរ៉ូដែលបោះពុម្ពផ្សាយនៅប្រទេសបារាំង (Edouard Lancereau, *Pancatantra*, Paris, Jannet, 1855 ; cf. Edouard Lancereau, *Pancatantra*, traduit du sanskrit et annoté par…,Connaissance de l′Orient, collection UNESCO, Paris, Gallimard, 1965, 383 p.)។

[9] *ប្រវត្តិពុទ្ធសាសនានៅកម្ពុជា*,អារម្ភបទដោយព្រះពោធិវង្សហួតតាត,ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦១, ១៥៧ទំព័រ។

ភិក្ខុប៉ាំងខាត់ជាសង្ឃជឿនលឿននិយម,មានគំនិតទូលំទូលាយដែលសិស្សអាចជជែកពិភាក្សា,ពិគ្រោះដោះស្រាយ,រិះគន់ស្ថាបនា,ប្តូរយោបល់។ល។ខុសនិងផ្ទុយពីព្រះសង្ឃក្នុងរាជាគណៈសង្ឃភាគច្រើន។

នាខែធ្នូឆ្នាំ១៩៤៨ពេលដែលពុទ្ធសាសនកជនដង្ហែអដ្ឋិធាតុព្រះមហាសាវកពីរអង្គគឺព្រះសារីបុត្តនិងព្រះមហាមោគ្គលានទៅកាន់ប្រទេសឥណ្ឌាដើម្បីត្រឡប់យកទៅតម្កល់នៅចេតិយដើមកំណើតវិញ។ពេលនោះព្រះភិក្ខុប៉ាំងខាត់សរសេរសំបុត្រមួយទៅអ្នកស្រីស៊ុយហ្សានកាប៉ឺឡែសសុំឲ្យដង្ហែ អដ្ឋិធាតុព្រះមហាសាវកពីរអង្គនេះកាត់តាមកម្ពុជាហើយសូមឲ្យអ្នកស្រីស៊ុយហ្សានកាប៉ឺឡែស ធ្វើអន្តរាគមន៍នៅសិរីលង្កាដើម្បីសូមចែករំលែកអដ្ឋិធាតុមួយចំនួនតម្កល់រក្សាទុកនៅប្រទេសកម្ពុជាសម្រាប់ជាសក្ការៈបូជារបស់ពុទ្ធសាសនិកជន។[10]

### ក្នុងនយោបាយ

ដោយលោកមានចរិតជា សង្ឃជឿនលឿននិយម,ឯករាជ្យនិយមចង់ឲ្យប្រជាពលរដ្ឋខ្មែរបានសុខសេរីភាពលោកនិងព្រះសង្ឃមួយចំនួនមានព្រះគ្រូអាចារ្យ**ហែមចៀវ**,ព្រះគ្រូអាចារ្យ**ខៀវជុំ**(វត្តលង្កា)[11], ព្រះគ្រូអាចារ្យ

---

[10] Cf. Archives Ecole Française d’Extrême Orient, Boîte 9 : « Suzanne Karpelès correspondance du Secrétaire général de l’EFEO le 28 décembre 1948 », « Les saintes reliques des deux disciples du Buddha (Sariputta et Mahàmoggqlànà) s’acheminent vers l’Inde, pour retourner dans leur stupa d’origine ». Lettre de Suzanne Karpelès au vénérable Pang Khat, Institut bouddhique à propos de sa demande de présenter les deux reliques aux Cambodgiens à l’occasion de leur déplacement au Royaume du Laos. Ils demandent à Suzanne Karpelès de faire à Ceylan les démarches nécessaires pour le partage des reliques avec eux « Vous seule, Mademoiselle, êtes capable de réaliser ces vœux nous sont si chers ».

[11] អាចារ្យខៀវជុំ (១៩១៥-១៩៧៥ ?)
កើតរវាងឆ្នាំ១៩១៥នៅខែត្រកណ្តាលក្នុងត្រកូលកសិករ។កុមារ ខៀវជុំបានបួសរៀនតាំងតែពីវ័យក្មេងខ្ចីហើយមានសាមណនាមជាឋានៈ*ធម្មបាលោ*មានន័យថាជា*អ្នករក្សាព្រះធម៌*។លោកអាចារ្យខៀវជុំ បានត្រូវតែងតាំងជា »ចៅអធិការវត្តលង្កា »ក្រុងភ្នំពេញរវាងឆ្នាំ១៩៧០និងឆ្នាំ១៩៧៥។ អាចារ្យ ខៀវជុំ បានចូលរួមក្នុងចលនាបាតុកម្ម"បដិវត្តន៍ឆ័ត្រ »នាថ្ងៃ២០កក្កដា១៩៤២ គឺជាមហាបាតុកម្មប្រឆាំងនឹងអាណានិគមបារាំងសេស។រដ្ឋអំណាចបារាំងបានចាប់លោកដាក់

សូរហាយ, ព្រះគ្រូអាចារ្យអ៊ុកជា[12]ជាដើមរួមជាមួយអ្នកនយោបាយជំនាន់នោះគឺមានលោកស៊ឹងង៉ុកថាញ់,លោកប៉ាចឈឺន,លោកនួនឌួង,លោកជុំមួង, លោកប៊ុណ្ណចន្ទម៉ុលជាអាទិ។[13] នៅឆ្នាំ១៩៤២ បាន ធ្វើ សកម្មភាពប្រឆាំងនឹងអាណានិគមបារាំងសេសដែលគេឲ្យឈ្មោះថា «បដិវត្តន៍ឆ័ត្រ»។[14]

ភិក្ខុប៉ាងខាត់ត្រូវអាជ្ញាបារាំងបង្ខំឲ្យសិក្ខ[15]ហើយបញ្ជូនទៅដាក់គុកនៅកោះត្រឡាចស្រុកយួនជាមួយ ព្រះគ្រូអាចារ្យហែមចៀវ. លោកប៊ុណ្ណចន្ទ

---

ពន្ធនាគារហើយបញ្ជូនទៅគុកកោះត្រឡាចនៅស្រុកយួន ជាមួយព្រះសង្ឃឯទៀតៗដូចជាអាចារ្យហែមចៀវ,អាចារ្យប៉ាំងខាត់ជាដើមព្រមទាំងអ្នកស្នេហាជាតិនានាឯទៀត។

លោក អាចារ្យ ខៀវជុំបានបន្សល់ទុកស្នាដៃជាច្រើនដូចជា:

១)*កម្ពុជវេយ្យាករណ៍*,បោះពុម្ពផ្សាយដោយភិក្ខុធម្មបាលោខៀវជុំ,នៅវត្តលង្កាក្រុងភ្នំពេញ,ពស២៥០៤,គស១៩៦២,១២៥២ទំព័រ។ <u>បណ្ណាល័យឯកជន</u>។

២)*វេយ្យាករណ៍យើង*,សម្រាប់បឋមសិក្សាបឋមភូមិអាទិកដ្ឋាន, បោះពុម្ពផ្សាយដោយទៀនហុងសេង, ក្រុងភ្នំពេញ,១៩៦៦,១៧៦ទំព័រ។ <u>បណ្ណាល័យឯកជន</u>។

៣)*ជីវិតតស៊ូ*,ក្រុងភ្នំពេញ,១៩៦៩, ក្រុងភ្នំពេញ ,សូមអាននៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យភ្នំពេញ លេខ២៩៣៨៩១០។ល។

[12] «ឯព្រះសង្ឃដែលស្នេហាជាតិមុតមាំគឺលោកអាចារ្យហែមចៀវសាស្ត្រាចារ្យភាសាបាលី,លោកគ្រូអាចារ្យប៉ាំងខាត់សាស្ត្រាចារ្យខាងភាសាសំស្ក្រឹត, លោកគ្រូអាចារ្យសូហាយក្រុមជំនុំព្រះត្រៃបិដក, លោកគ្រូអាចារ្យអ៊ុកជា, លោកគ្រូអាចារ្យខៀវជុំ(ពីរអង្គនេះគង់វត្តលង្កា)ជាដើម។» ប៊ុណ្ណចន្ទម៉ុល,*គុកនយោបាយ*,ភ្នំពេញ,១៩៧១,ទំព័រ៣២-៣៣។

[13] សូមអានប៊ុណ្ណចន្ទម៉ុល,*គុកនយោបាយ*,ភ្នំពេញ,១៩៧១,២៧១ទំព័រ។

[14] Henri LOCARD, « Haem Chiev (1898-1943) the ‘Umbrella Demonstration’ of 20th July 1942 and the Buddhist Institue under the Vichy régime », in : *Researching Buddhism and Culture in Cambodia*, 1930-2005, *The Buddhist Institute Colloquium*, Phnom Penh, June 2005, p. 20-18)

[15] «ចំណែក លោកគ្រូអាចារ្យប៉ាំងខាត់ដោយបារាំងចេះតែសង្កត់សង្កិនស៊ើបសួរពេកក៏លាសិក្ខាបទ ទៅនៅសំណាក់នឹងវត្តពិទូវង្សី(ចិនដំដែក)ហើយទីបំផុតក៏សម្រេចចិត្តដើរចូលក្រសួងធម្មការប្រគល់ខ្លួនឲ្យគេចាប់តែម្តង» ប៊ុណ្ណចន្ទម៉ុល,*គុកនយោបាយ* , ភ្នំពេញ,១៩៧១,ទំព័រ៦២។

ម៉ុលនិងសហសេរិកឯទៀតៗ។[16]នៅឆ្នាំ១៩៥៤លោកបានរួចពីពន្ធនាគារកោះត្រឡាចមកកាន់មាតុប្រទេសវិញ។[17]

នៅ«សម័យសាធារណរដ្ឋខ្មែរ»(១៩៧០/១៩៧៥)[18] ភិក្ខុប៉ាងខាត់មានតួនាទីយ៉ាងសកម្មក្នុងនយោបាយជាតិនៅសម័យនោះគឺលោកចូលប្រជុំជាមួយគណៈរដ្ឋមន្ត្រីជាច្រើនលើកច្រើនគ្រា ហើយលោកបានចេញឃោសនា ការពារនយោបាយ រដ្ឋអំណាចរបបសាធារណរដ្ឋខ្មែរ។[19] នៅសម័យនោះភិក្ខុប៉ាងខាត់រមែងទស្សនាវលែកទុក្ខគ្រួសារយុទ្ធជនដែលបានបូជាជីវិតក្នុងសមរភូមិឧទាហរណ៍ដូចជាសំដែង ធម្មទេសនានាបុណ្យទក្ខិណានុប្បទានរបស់ព្រិន្ទបាលទោអូប៊ិនឆេងអួននៅវត្តបូព៌សម័យសាធារណរដ្ឋខ្មែរស្តីពីវេទនាសង្ខារវិញ្ញាណនិងខន្ធ។ល។[20]

---

[16] សូមអានសៀវភៅរៀបរៀងដោយគង់សម្ភារ,*ព្រះបាឡាត់ឃោសនាគហែមចៀវ,វីរបុរសជាតិ,* (រៀបរៀងតាមឯកសាររបស់លោកប៉ែនយុត្តិចាងហ្វាងសារពត៌មានប្រជាជាតិ,តាមថេរដីកាព្រះសង្ឃចាស់ៗជាច្រើនអង្គ,លោកប៊ុនចន្ទម៉ុល,លោកឈឹមស៊ុមអតីតសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ដែលរួមបាតុកម្មតវ៉ាឱ្យបាវាំងលែងអាចារ្យហែមចៀវមកវិញ។),ពិនិត្យវិញដោយព្រះពោធិវង្សស្វរហាយ,ភ្នំពេញ,១៩៧២,ការផ្សាយឡើងវិញរបស់សារពត៌មានអង្គរបូរីនៅព.ស.២៥៤៥។

[17] «មកដល់កំពង់ចម្លងអ្នកលឿងក៏បានជួបនឹងលោកគ្រូប៉ាងខាត់,ជុំមួងព្រមទាំងមិត្តភក្តិឯទៀត។យើងទាំងអស់គ្នាឱបរឹតគ្នាដោយសេចក្តីត្រេកអរជាតិយោ្យភាព។តើមានពាក្យអ្វីថ្លែងឲ្យចំបានអំពីមនោសញ្ចេតនាសប្បាយរីករាយដោយសារបានជួបគ្នានេះ ?គ្មានឡើយ យើងសប្បាយណាស់រកពាក្យថ្លែងពុំបាន។» ប៊ុណ្ណចន្ទម៉ុល,*គុកនយោបាយ* , ភ្នំពេញ,១៩៧១,ទំព័រ២៦៣-២៦៤។

[18] «សម័យសាធារណរដ្ឋ»សូមអានសៀវភៅលោក Ros Chantrabot, *La République khmère*, Paris, L'Harmattan, 1993, 217 p.(រស់ចន្ទ្រាបុត្រ,*សាធារណរដ្ឋខ្មែរ*,ប៉ារីស, ឡាម៉ាតង់,១៩៩៣,២១៧ទំព័រ)។

[19] Cf. « La guerre populaire », *Khmer Republic* (Revue mensuelle illustrée du Cambodge moderne), vol. 1, n° 1, septembre 1971, p. 54 ; *Cambodge Nouveau*, « Les événements au jour le jour », p. 23.

[20] cf. *KKC Radio Webcast* ; Dharma Talk : The Most viniya Pandito Pang Khat, former Professorat Sihanouk ràja University and Wat Ounaloam Literature University in Phnom Penh
( www. Khmerkromgo.org/multimedia/media/webcast.htm)

ស្នាដៃសំខាន់ៗ៖

ព្រះមហាវិរិយបណ្ឌិតោប៉ាំងខាត់ ៖

- *មគ្គុទ្ទេសក៍នគរ* (Guide d'Angkor) អាចារ្យប៉ាំងខាត់,ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ,១៩៤១,២ភាគ,ភាគ១,៥៣ទំព័រ,ភាគ២,២២២ ទំព័រ។ បោះពុម្ពឡើងវិញនៅ ពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩៥៧,ភាគ ១មាន៤៧ទំព័រ,ភាគ២មាន១៩៨ទំព័រ។
- គួរកសាងអនុស្សាវរីយ៍ព្រះមហាវិមលធម្មថោងឬទេ ?,*ទស្សនាវដ្ដីមិត្តសាលាបាលី*,១៩៥១,លេខ១,ទំព័រ២២,៣៥។
- បញ្ចតន្ត្រ:, សេចក្ដី ប្រែ របស់ ភិក្ខុ ប៉ាំងខាត់ ,*ទស្សនាវដ្ដីមិត្តសាលាបាលី*,១៩៥១ដល់១៩៥៥,លេខ១, មាន ច្រើន លេខតាំងតែកំណើត *ទស្សនាវដ្ដីមិត្តសាលាបាលី* ពី១៩៥០រៀងរហូតគ្រប់លេខរហូតដល់រលត់ជីវិតរវាងឆ្នាំ១៩៥៥តែរកមិនឃើញនៅបណ្ណាល័យនានាឱ្យបានគ្រប់លេខទេ។ចាប់ពីឆ្នាំ១៩៥៦ទស្សនាវដ្ដីនេះបានដូរឈ្មោះជា *ទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ*វិញហើយមានបណ្ណាធិការនាមហួតហៀម។
- « ព្រះពុទ្ធសាសនាគឺអ្វី ? »,*ទស្សនាវដ្ដីមិត្តសាលាបាលី*,១៩៥១, លេខ៤,៥,ទំព័រ១៥៦ដល់១៧៤។ លេខ៦,៧,ទំព័រ២៨៥ដល់២១៦។
- « បុណ្យគឺអ្វី ? »,*ទស្សនាវដ្ដីមិត្តសាលាបាលី*,១៩៥១,លេខ៨,៩, ទំព័រ២៨៥ដល់៣០៧។
- *ស្រីហិតោបទេស*, ភ្នំពេញ, គីមគី, ៤ភាគ,១៩៥២-១៩៦១,កថាមុខសរសេរចប់នៅវត្តឧណ្ណាលោមថ្ងៃពុធ៦រោចខែភទ្របទឆ្នាំឆ្លូវឯកស័កពស២៤៩២ត្រូវនឹងថ្ងៃទី២៧ខែកញ្ញាគស១៩៤៩។ បោះពុម្ពឡើងវិញនៅ ពុទ្ធសាសនបណ្ឌិត្យ១៩៩៩។ផ្សាយ ឡើងវិញតាមប្រព័ន្ធអាំងទែណែត (http://choukhmer.blogsome.com)។
- *ជីវិតមនុស្ស*, ភ្នំពេញ,រោងពុម្ពខ្មែរ,១៩៥២,៨៩ទំព័រ។
- *ប្រវត្តិពុទ្ធសាសនានៅកម្ពុជា*,អារម្ភបទដោយព្រះពោធិវ័ង្សហួតតាត,ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦១, ១៥៧ទំព័រ។

- “Le bouddhisme au Cambodge” (en français rédigé à l’occasion de l’entrée en l’année 2500 de l’ère bouddhique), *France-Asie* : *Présence du bouddhisme*, n° 153-157, tome XVI, Saigon, 1959, p. 841-852, ré-édité par le Centre d’Etudes Bouddhiques au Cambodge, Phnom Penh, Institut Bouddhque; 1963, p. 41-68 (ré-édité par Réné de BERVAL (éd.), *Présence du bouddhisme*, Paris, Gallimard, 1987.)

  \- *Le Bouddhisme au Cambodge*, ré-édité,.Phnom Penh, 1970, Edition Institut Bouddhique, collection "Série de Culture et Civilisations Khmères", n° 9, 26 p.
- *ជីវិតម៉ែ*, ភ្នំពេញ, បោះពុម្ពលើកទី២, ១៩៦៤ (បោះពុម្ពឡើងវិញនៅ Austin, Texas ដោយមូលនិធិកម្ពុជា, ១៩៨៦,បទដើមដោយលោកកុលផេង)។
- *វប្បធម៌អរិយធម៌ខ្មែរឥណ្ឌា* , ភ្នំពេញ, ១៩៦៨, ២៧១ ទំព័រ។
- *កើតទៀតឬទេ?*, ភ្នំពេញ,វត្តឧណ្ណាលោម,១៩៦៩,១០៥ទំព័រ។
- *ការត្រាស់ដឹង*, ភ្នំពេញ, អ្នកនិពន្ធ,១៩៦៩,៣៩ទំព័រ។

  - *ពុទ្ធសាសនាដូចម្តេច?*, ភ្នំពេញ,ផ្សាយដោយឌឹកគាម,១៩៦៩ ។ ផ្សាយឡើងវិញដោយសំរិដ្ធានៅ២៥មេសា ២០០៩នៅសហរដ្ឋអាមេរិកក្នុងប្រពន្ធអាំងទែណែត ។
- *ពុទ្ធសាសនាជាវិទ្យាសាស្ត្រ* ?, ភ្នំពេញ, អ្នកនិពន្ធ,១៩៧២,៦០ ទំព័រ។
- *ព្រះត្រៃបិដកជាភាសាខ្មែរ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ,១៩៩៥, បោះពុម្ពឡើងវិញ។
- *មនុស្សចង់បានអ្វី*?, ភ្នំពេញ,មជ្ឈមណ្ឌលវិប្បស្សធុរៈកម្ពុជា, ១៩៩៩,៣៨ទំព័រ, បោះពុម្ពឡើងវិញ។
- សហការណ៍នឹងនួនប៊ុត, *វចនានុក្រមខ្មែរ (Dictionnaire cambodgien)*,ភ្នំពេញ, បណ្ណាគារប៊ុតនាង១៩៥៤,១៩០១ទំព័រ។

*អត្ថបទសិក្សាផ្សាយក្នុងទស្សនាវដ្តី*កម្ពុជសុរិយា*៖
- "អរិយសច្ចៈជាពុទ្ធភាសិត", *កម្ពុជសុរិយា,* ១៩៤៥,ក្បាលទី១,ឆ្នាំទី១៧,ទំព័រ៥២ដល់៥៦។

- *ដដែល*
, ទំព័រ១០៩ដល់១១៣។
- *ដដែល*(ត)
, ទំព័រ១៥៦ដល់១៦៥។
- *ដដែល*(ត)
,ទំព័រ១៩៦ដល់២០៩។
- *ដដែល*(ត)
,ទំព័រ២៧៥ដល់២៨០។
- *ដដែល*(ត)
, ទំព័រ៣២៧ដល់៣៣៣។
- *ដដែល*(ត) , *កម្ពុជសុរិយា,* ១៩៤៥,ក្បាលទី២,ឆ្នាំទី ១៧ , ទំព័រ៣៩៣ដល់៣៩៤។
- *ដដែល*(ត)
, ទំព័រ៤៤៥ដល់៤៥០។
- *ដដែល*(ត)
, ទំព័រ៦៥៣ដល់៦៦២។
- *ដដែល*(តចប់) , ទំព័រ៧០៥។
- "ពុទ្ធសាសនានៅប្រទេសខ្មែរ", *កម្ពុជសុរិយា,* ១៩៥៦,លេខ១១, ទំព័រ១០០៣ដល់១០១៩។
- ដដែល(តចប់) ,លេខ១២ ,ទំព័រ១១០៣ដល់១១២៣។
- "ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ", *កម្ពុជសុរិយា,* ១៩៥៨,ក្បាល ទី១,លេខ២, ទំព័រ៩៧ដល់១០០។
- ដដែល(ត)
, ទំព័រ១៩៣ដល់១៩៨។

- *ដដែល*(ត) ,
លេខ៥,ទំព័រ២៨៩ដល់២៩៨។
- *ដដែល*(ត) ,ក្បាលទី
២,លេខ១, ទំព័រ៣៨៣ដល់៣៩៨។
- *ដដែល*(ត) ,
លេខ២, ទំព័រ៤៧៩ដល់៤៩៤។
- *ដដែល*(ត) ,
លេខ៣, ទំព័រ៥៧៥ដល់៥៨៦។
- *ដដែល*(ត) ,
លេខ៤, ទំព័រ៦៧៥ដល់៦៨០។
- *ដដែល*(ត) ,
លេខ៥, ទំព័រ៧៥៥ដល់៧៦២។
- *ដដែល*(ត) ,
លេខ៦, ទំព័រ៨៥១ដល់៨៦៦។
- *ដដែល*(ត) ,
លេខ៧, ទំព័រ៩៤៧ដល់៩៥៦។
- *ដដែល*(តចប់)
,លេខ៨, ទំព័រ១០៤៣ដល់១០៥៣។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៥៩,លេខ២,ទំព័រ
២៣៤/២៣៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៥៩,លេខ៣,ទំព័រ
៣៥២/៣៥៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៥៩,លេខ៤,ទំព័រ
៤៧៦/៤៨០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៥៩,លេខ៥,ទំព័រ
៦០០/៦០៤។

- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ៦,ទំព័រ ៧៦១/៧២៤។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ៧,ទំព័រ ៨៣៨/៨៤៥។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ៨,ទំព័រ ៩៥៨/៩៤៥។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ៩,ទំព័រ ១០៧៦/១០៨០។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ១០,ទំព័រ ១២០៤/១២០៥។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ១១,ទំព័រ ១៣២០.១៣២១។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៥៩,លេខ១២,ទំព័រ ១៤៤៤។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៦០,លេខ១, ទំព័រ ១១៨/១២០។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៦០,លេខ២,ទំព័រ ២៣៨/២៤០។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៦០,លេខ៣,ទំព័រ ៣៥៤/៣៦០។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៦០,លេខ៤.ទំព័រ ៤៨០/៤៨២។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា* ,១៩៦០,លេខ៤,ទំព័រ៣៩៦១/៣៧៦។
- ‶វចនានុក្រមសំស្រ្កឹតខ្មែរ″ *កម្ពុជសុរិយា,* ១៩៦០,លេខ៥,ទំព័រ ៥៩៨/៦០០។
- «ពុទ្ធជីវប្បវត្តិ»,កម្ពុជសុរិយា*,* ១៩៦០,លេខ៥, ទំព័រ៤៨៣/៤៩៣។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា ,* ១៩៦០,លេខ៦, ទំព័រ៦០៨/៦១៦។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦០,លេខ៦,ទំព័រ ៧១៨។

<u>សេចក្តីសង្កេត</u>៖ទស្សនាវដ្តី *កម្ពុជសុរិយា,* ១៩៦០ខ្វះលេខ៧ដល់លេខ ១២នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ។

- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា,* ១៩៦១,លេខ១, ទំព័រ១/១៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ១,ទំព័រ ៥៩/៦០។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា,* ១៩៦១,លេខ២, ទំព័រ១១៩/១៣៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ២,ទំព័រ ២០៥។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា,* ១៩៦១,លេខ៣, ទំព័រ២៣៧/២៥៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៣,ទំព័រ ២៩១។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា,* ១៩៦១,លេខ៤, ទំព័រ៣៥៧/៣៦៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៤,ទំព័រ ៤១៧។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា ,* ១៩៦១,លេខ៥, ទំព័រ៤៩០/៤៩៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៥,ទំព័រ ៥២៩។
- «ពុទ្ធជីវប្បវត្តិ», *កម្ពុជសុរិយា,* ១៩៦១,លេខ៦, ទំព័រ៦០៨/៦១៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៦, ទំព័រ៦៦៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៧,ទំព័រ ៧៨៣។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៨,ទំព័រ ៨៩៨។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៩,ទំព័រ ១០២០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ១០,ទំព័រ ១១២៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦១,លេខ៥,ទំព័រ ១១២៦។

(*កម្ពុជសុរិយា,* ១៩៦១,លេខ១២,ឥតមានចុះអត្ថបទ "វចនានុក្រមសំស្រ្កឹតខ្មែរ"ទេ។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ១,ទំព័រ ៤៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ២,ទំព័រ ២០៤។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៣,ទំព័រ ៣១៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៤,ទំព័រ ៤៣៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៥,ទំព័រ ៥៦៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៦,ទំព័រ ៦៨៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៧,ទំព័រ ៧៩២។
- «សិលាចារឹកនៅប្រាសាទវិមានអាកាស», *កម្ពុជសុរិយា,* ១៩៦២, លេខ៨,

ទំព័រ៩១៥/៩២៣។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៨,ទំព័រ ៩៣៩។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ៩,ទំព័រ ១០៣០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ១០,ទំព័រ ១១៥៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ១១,ទំព័រ ១២៥៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦២,លេខ១២,ទំព័រ ១៣៨៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ១,ទំព័រ ៥៩/៦០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ២,ទំព័រ ១៨៩/១៩០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៣,ទំព័រ ២៨៦/២៨៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៤,ទំព័រ ៣៩៩/៤០០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៥,ទំព័រ ៥២៦/៥២៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៦,ទំព័រ ៦១៦/៦១៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៧, ទំព័រ៧០១/៧០២។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៨, ទំព័រ៧៩៥/៧៩៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ៩,ទំព័រ ៩៤៥/៩៤៦។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ១០,ទំព័រ ១០៤៧/១០៤៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ១១,ទំព័រ ១១៤៩/១១៥០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៣,លេខ១២,ទំព័រ ១២៥៧/១២៥៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៤,លេខ១,ទំព័រ ៤១/៤២។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៤,លេខ២,ទំព័រ ១៦១/១៦២។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៤,លេខ៣,ទំព័រ ២៨៦/២៨៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៤,លេខ៤,ទំព័រ ៣៩៩/៤០០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៤,លេខ៥,ទំព័រ ៥១៣/៥០០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៤,លេខ៦,ទំព័រ ៦២៧/៦២៨។

សេចក្ដីសង្កេត៖ទស្សនាវដ្ដី *កម្ពុជសុរិយា,* ១៩៦៤ខ្វះលេខ៧ដល់លេខ ១២នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ។

- "ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ",*កម្ពុជសុរិយា,*១៩៦៥,លេខ១,ទំព័រ ១៩/២៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ១,ទំព័រ ៣៩/៤០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ២,ទំព័រ ១៦៦/១៦៧។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ៣,ទំព័រ ២៦២/២៦៣។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ៤, ទំព័រ៣៥៥/៣៥៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ៥,ទំព័រ ៤៦០/៤៦១។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ៦,ទំព័រ ៥៧៤/៥៧៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ៧, ទំព័រ៧០២/៧០៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ៨,ទំព័រ ៧៩៦/៧៩៩។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៥,លេខ១,ទំព័រ

<u>សេចក្តីសង្កេត</u>៖ទស្សនាវដ្តី *កម្ពុជសុរិយា,* ១៩៦៥ខ្វះលេខ៩ដល់លេខ ១២នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ១,ទំព័រ ៣៤/៣៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ២,ទំព័រ ១៦០/១៦១។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ៣,ទំព័រ ២៧៤/២៧៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ៤,ទំព័រ ៣៧៧/៣៧៩។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ៥,ទំព័រ ៤៩៣/៤៩៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ៦, ទំព័រ៦៣១/៦៣៤។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ៧, ទំព័រ៧២៥/៧២៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ៨, ទំព័រ៨៣៣/៨៣៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,*១៩៦៦,លេខ៩, ទំព័រ៩២១/៩២៤។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ១០,ទំព័រ ១០៣៧/១០៤០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ១១,ទំព័រ ១១៣៦/១១៣៩។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៦,លេខ១២,ទំព័រ ១២៥០/១២៥៣។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ១, ទំព័រ៣៣/៣៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ២, ទំព័រ១៤៧/១៥០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ៣,ទំព័រ ២៦៧/២៧០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ៤,ទំព័រ ៣៨៥/៣៨៨។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ៥,ទំព័រ ៤៩៣/៤៩៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ៦, ទំព័រ៦៣៨/៦៤១។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ៧, ទំព័រ៧១៦/៧១៩។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៧,លេខ៨,ទំព័រ ៨១២/៨១៥។

<u>សេចក្តីសង្កេត</u>៖ ទស្សនាវដ្តី *កម្ពុជសុរិយា,*១៩៦៧ខ្វះលេខ៩ដល់លេខ១២នៅ បណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៨,លេខ១,ទំព័រ ៤៧/៥០។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៨,លេខ២,ទំព័រ ១៨១/១៨៤។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៨,លេខ៣,ទំព័រ ២៧៣/២៧៦។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៨,លេខ៤,ទំព័រ ៣៧៧/៣៨។

<u>សេចក្តីសង្កេត</u>៖ ទស្សនាវដ្តី *កម្ពុជសុរិយា,*១៩៦៨ខ្វះលេខ៥ដល់លេខ១២នៅ បណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ១,ទំព័រ ៣២/៣៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ២,ទំព័រ ១២៨/១៣១។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ៣,ទំព័រ ២៥៩/២៦២។
- លេខ៤,១៩៦៩,ឥតមានអត្ថបទវិរិយបណ្ឌិតោប៉ាងខាត់ទេ។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ៥,ទំព័រ ៤៨៩/៤៩២។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ៦,ទំព័រ ៥៨៦/៥៨៩។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ៧,ទំព័រ ៦៨៨/៦៩០។

- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ៨,ទំព័រ ៨១៤/៨១៦។
- «ទស្សនវិជ្ជាពុទ្ធសាសនា», *កម្ពុជសុរិយា,* ១៩៦៩,លេខ៩, ទំព័រ៩០៣/៩១៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ៩,ទំព័រ ៩៣៣/៩៤៤។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ១០,ទំព័រ ១០៧៤/១០៧៧។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ១១,ទំព័រ ១២១៦/១២១៩។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៦៩,លេខ១២,ទំព័រ ១២៩២/១២៩៥។
- "វចនានុក្រមសំស្រ្កឹតខ្មែរ" *កម្ពុជសុរិយា,* ១៩៧០,លេខ១,ទំព័រ ៣១៖៣៣។
- "កើតទៀតឬទេ? "(ត), *កម្ពុជសុរិយា,* ១៩៧០,លេខ២,ទំព័រ ១២៥/១៣៧។
- "កើតទៀតឬទេ? "(ត) ,*កម្ពុជសុរិយា,* ១៩៧០,លេខ៣,ទំព័រ ២៤៣/២៦២។
- "កើតទៀតឬទេ? "(ត), *កម្ពុជសុរិយា,* ១៩៧០,លេខ៤,ទំព័រ ៣៥១/៣៦៥។
- "កើតទៀតឬទេ? "(ត) *កម្ពុជសុរិយា,* ១៩៧០,លេខ៥,ទំព័រ ៤៦៧/៤៨៧។
- "កើតទៀតឬទេ? "(ត) *កម្ពុជសុរិយា,* ១៩៧០,លេខ៦,ទំព័រ ៥៨១/៥៨៧។
- "កើតទៀតឬទេ? "(ត) *កម្ពុជសុរិយា,* ១៩៧០,លេខ៧,ទំព័រ ៦៨៧/៧២០។

- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧០,លេខ១០,ទំព័រ ៨១៩/៨២៩។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧០,លេខ១១,ទំព័រ ៨៩៩/៩១០។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧០,លេខ១២,ទំព័រ ៩៩៩/១០០៩។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ១,ទំព័រ៧/១៥។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ២,ទំព័រ៧៥/៧៩។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៣,ទំព័រ ១៣៦/១៤៣។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៤,ទំព័រ ២០៧/២១១។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៥,ទំព័រ ២៥៥/២៧០។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៦,ទំព័រ ៣១៣/៣២១។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៧,ទំព័រ ៥៨៩/៥៩២។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៨, ទំព័រ៦២៧/៦៣០។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ៩, ទំព័រ៦៧៩/៦៨១។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ១០,ទំព័រ ៧៣៤/៧៣៧។
- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ១១, ទំព័រ៧៧៤/៧៧៧។

- «ចតុរារិយសច្ចៈ», *កម្ពុជសុរិយា,* ១៩៧១,លេខ១២,ទំព័រ ៨២២/៨២៥។

តាមការនឹកឃើញរបស់លោកមហាឡាយគ្រីស្នាដៃព្រះភិក្ខុប៉ាង ខាត់មានដល់ទៅ៣៥ចំណងជើងតែយើងបានរកឃើញ មួយចំនួនធំ ហើយអត្ថបទខ្លះទៀតឥតឃើញមានក្នុងបញ្ជីមហាឡាយគ្រីទេ។[21]

[21] សូមអាន″បទដើម″របស់ភិក្ខុឡាយគ្រីហៅកូក្នុងសៀវភៅរិរិយបណ្ឌិតោប៉ាងខាត់*ជីវិតម៉ែ* បោះពុម្ពនៅភ្នំពេញ១៩៦៤ក្នុងទំព័រ″ង″និង″ច″។




ព្រះមហាវិរិយបណ្ឌិតោប៉ាងខាត់ថតជាមួយនិស្សិតជំនាន់ឆ្នាំ
១៩៦៧



ព្រះមហាវិរិយបណ្ឌិតោប៉ាងខាត់រួមក្នុងការជំនុំនយោបាយជាមួយគណៈរដ្ឋមន្ត្រីសាធារណរដ្ឋខ្មែរក្រោមអធិបតីភាពអ្នកអង្គម្ចាស់ស៊ីសុវត្ថិសិរិមតៈនាឆ្នាំ១៩៧០/៧១



ព្រះមហាវិរិយបណ្ឌិតោប៉ាងខាត់កំពុងឃោសនានយោបាយឲ្យរដ្ឋាភិបាល
សាធារណរដ្ឋខ្មែរ